**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

**MINISTRY OF INFORMATION**

លេខ : ៣៧៥ ព.ម/ប្រក

ថ្ងៃ អង្គារ ៦ រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨

# ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦/០៩/១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨/០៦/១៨ ប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ /០៩/៩៥ ប្រកាសឲ្យប្រើច្បាប់ស្ដីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១២ ចុះថ្ងៃទី២៤ /០១/៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.បក ចុះថ្ងៃទី០៥/០៨/៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣/០៧/០៧ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងពាក្យស្នើសុំបើកអាជីវកម្មទស្សនាវដ្ដីឈ្មោះ "ស្វែងរកការពិត" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ របស់លោក សោម ប៊ុនថន ។

## <u>សម្រេច</u>

**ប្រការ១** : អនុញ្ញាតឲ្យលោក សោម ប៊ុនថន សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩០៨៥៣១៤១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ អាសយដ្ឋាននៅភូមិតាណារ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង បើកអាជីវកម្ម៖
- ទស្សនាវដ្ដីឈ្មោះ "ស្វែងរកការពិត" បោះពុម្ពផ្សាយជាខេមរៈភាសា និងភាសាអង់គ្លេស
- មានអាសយដ្ឋានទីស្នាក់កានៅផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភូមិ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ បទប្បញ្ញត្តិច្បាប់ ច្បាប់ស្ដីពីរបបសារព័ត៌មាន ច្បាប់ស្ដីពីកម្មសិទ្ធិបញ្ញា នៃព្រះរាជាណាចក្រកម្ពុជា សេចក្ដីណែនាំ កិច្ចសន្យា ក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាសយដ្ឋានទីស្នាក់ការទស្សនាវដ្ដី ឈ្មោះចាងហ្វាង ការផ្សាយ និងឈ្មោះអាសយដ្ឋានរោងពុម្ពនៅលើទំព័រទស្សនាវដ្ដីរបស់ខ្លួន ព្រមទាំងយកទស្សនាវដ្ដីមួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន និងចំនួន០២ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ។

**ប្រការ៣** : ករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤** : ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ខុទ្ទកាល័យ នៃក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ សាមីខ្លួន និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**រដ្ឋមន្ត្រី**

<u>ចម្លងជូន</u>
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (អគ្គស្នងការនគរបាលជាតិ)
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មាន
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

**អ៊ុក-ប្រាថ្នា**